# រឿង មហាចោរនៅទល់ដែន

## ភាគទី១៦

នាងទេវី និង នាងក្លួងបានបីបាច់រក្សាកូនស្រីយ៉ាងហ្មត់ចត់ ។ នាងទាំងពីរបានដាក់ឈ្មោះកុមារីថា បទុម ។ រាល់ថ្ងៃ នាងទេវីឱបក្រសោបនាងបទុមជាប់នៅនឹងដើមទ្រូង។ ធីតាពុំឲ្យបុត្រីកំព្រានេះឃ្លាតឆ្ងាយបានឡើយ។ នាងតែងបំពេកែវជាបុត្រីឲ្យគេងលក់ស្កប់ស្កល់រាល់ថ្ងៃ ដោយបានបំបៅស្រីឲ្យបានឆ្អែតឆ្អល់ជានិច្ច។ នាងតែងបបោសអង្អែលកូន ក្រែងមានសត្វស្រមោចសង្កាខាំ។ នាងថើបស្រី ជាបុត្រភ្ងា។

ជីវិតនាង និង ជីវិតកុមារី រួមចូលគ្នាជាផ្លុងមួយដែលវេញគ្នាយ៉ាងត្របាញ់អស្ចារ្យ ។ បុត្រីនេះជាព្រលឹងរបស់ធីតា ។ ក្នុងរូបដ៏តូចច្រឡឹងនេះទេវីហាក់ឃើញជីវិតនាងបន្តសង្ខារទៅមុខទៀត។ បុត្រីនេះហើយ ជាថ្នាំទិព្វមួយដែលរំលាយទុក្ខ បំភ្លេចសេចក្តីព្រួយរបស់នាងរួចធ្វើឲ្យរស់រៀងតទៅ។ កុមារីចេះញញឹមយ៉ាងស្រស់ប្រិមប្រិយហើយ។ កែវចេះឆ្លើយឆ្លងបន្តិចៗ នឹងនាងដែលជាហេតុរឹតតែឲ្យនាងស្រលាញ់ថែមទៀត។ ឱ! សេចក្តីស្នេហានៃមាតាចំពោះបុត្រ គ្មានវត្ថុក្នុងនាលោកនេះអាចប្រៀបផ្ទឹមបានឡើយ។ តាំងពីបានបុត្រីកំសត់នេះមក នាងទេវីកើតទុក្ខតែនាងសប្បាយយ៉ាងអនេក ។ នាងកើតទុក្ខក្នុងសង្គម ព្រោះនាងព្រាត់ប្រាស់ឪពុក ព្រាត់ប្រាស់ប្តីសម្លាញ់ ។ ម្យ៉ាងទៀត ព្រោះកាមាជាមនុស្សបានមកយាយីដល់រូបនាងរាល់ពេលវេលា រហូតដល់បណ្តេញនាងឲ្យចេញពីភូមិឋានផ្ទះសំបែង។ នាងសប្បាយសប្បាយព្រោះក្នុងសង្គមដដែលនេះ អរុណមួយថ្មីរះក្នុងជីវិតនាង គឺនាងបទុមតែមួយនេះ។

មែននាងសប្បាយមែន សប្បាយប្រហែលលើសអស់មាតាទាំងពួង។ ណាមួយកុមារីប្រកបដោយសុខភាពបរិបូណ៌ មានសំណើចស្រស់ចិញ្ចាច មានសាច់សស្អាត មានសម្តីរអាក់រអួលបន្តិចផង គួរជាទីស្នេហាប្រាកដ។ បទុមបានមួយខែហើយ។ ថ្ងៃនេះនាងទេវីបំបៅបុត្រី ។ នាងដាក់កូនទៅក្នុងអង្រឹង រួចមាតាកម្សត់ដេកយោលកូនដែលលក់ស្កប់ស្កល់។ មិនយូរប៉ុន្មាន នារីជាមាតាក៏លង់លក់ទៅជាមួយកូនដែរ។ ស្រីយល់សប្តិឃើញមាននរជាប្តីនាងមកឱបក្រសោបនាង។ ធីតាយំដាយរឭកប្តីខ្លាំងពេក។ ទេវីលង់លក់ក្នុងដំណេក។ លុះដល់នាងភ្ញាក់ដឹងខ្លួនឡើង ព្រះសុរិយាជ្រៀងជ្រេណាស់ទៅហើយ។ នាងទាញអង្រឹងយោល

អត្ថបទដោយ៖ មាស សុភាព

បទុមជាបុត្រី ។ តែ! អ្វីក៏ដូច្នោះ? អង្រឹងទ្រង់ស្រាលស្ញើក។ ធរីក្រោកឡើងដូចគេកន្ត្រាក់។ បាត់បុត្រីទៅណាហើយកែវកូនអើយ។ កែវល្អស្អុះចេញទៅក្រៅស្រែកហៅមីងក្លួង តែខាងក្រៅស្ងាត់ឈឹង ។ យាយក្លួងទៅផ្សារពុំទាន់មកផង។ នាងនឹកថា ប្រហែលយាយក្លួងមកលើកកូនយកទៅមុជទឹកឯស្ទឹងហើយ ។ ស្រីរត់ទៅរកស្ទឹង តែគ្មានឃើញអ្វីសោះ។ នាងសួរអ្នកឯទៀតដែលនាងជួបប្រទះថា «ឃើញអ្នកណាមកយកកូនខ្ញុំទេ?» គេឆ្លើយថា «ទេ!... យ៉ាងណាដូច្នោះ?»។ ទេវីកំសត់ពន្យល់ប្រាប់គេវិញពុំទាន់ចប់ផង នាងរត់ទៅសួរអ្នកជិតខាងទៀត។ នារីឆ្វេឆ្វា បីដូចមេមាន់រកពង។ មុខនាងឡើងស្លាំងត្បិតអ្នកទាំងពួងឆ្លើយមកនាងវិញតែពាក្យដដែល។ មិនយូរប៉ុន្មានមនុស្សក្នុងភូមិជួយឆោឡោរកបុត្រីរបស់នាងទេវី ។ នាងក្លួងមកដល់ទៀត ក៏ជួយរកទៀត។ ទឹកភ្នែកហូរសស្រាក់ នាងទេវីស្រែកទ្រហោយំថា៖

- ឱ! ម្ចាស់ថ្លៃអើយ លោកអ្នកណាយកកូនខ្ញុំទៅ? ខ្ញុំលង់ដំណេកភ្ញាក់ឡើងស្រាប់តែបាត់កូន។ ឱ! អ្នកណានោះអីក៏ចិត្តអាក្រក់ម្ល៉េះ? លួចអីមិនលួច ៗកូនខ្ញុំ។ កូនទើបបានមួយខែថ្ងៃនេះផង។ ឱ! តើនាងបានអីបៅ តើគេយកថ្លៃទៅសម្លាប់ចោលរឺអ្វី?។ កូន ៗ! ទើបបានឃើញពន្លឺព្រះអាទិត្យមិនបានប៉ុន្មានថ្ងៃផង ស្រាប់តែវិនាសទៅវិញ។ នាងពុំទាន់ចេះនិយាយ ចេះគិតគូរផង ស្រាប់តែបាត់ទៅ។ ឱ! លោកអ្នកអើយជួយកូនខ្ញុំផង ខ្ញុំស្លាប់ក្នុងពេលនេះជាប្រាកដហើយ ។ ពូមីងអើយ! ជួយយោងជីវិតខ្ញុំផង។ ខ្ញុំគ្មានទ្រព្យធនអ្វីទេ។ ខ្ញុំមានតែកូនមួយនេះ។

នាងទេវីដើរបណ្តើរ យំបណ្តើរ ពីផ្ទះមួយទៅផ្ទះមួយ រៀបរាប់សព្វគ្រប់ ។ អ្នកផងដែលស្តាប់ក៏ជួយយំផងគ្រប់ៗគ្នា។ រាត្រីក៏ដណ្តប់ពិភពលោកធ្វើឲ្យងងឹតស្លុង ។ នាងទេវីរឹងរឹតតែខ្វាចផ្សាទៅទៀត ។ នាងដើរពេញភូមិសួរគេ។ ដោយពុំឃើញ នាងដើរទៅដល់ព្រៃក្រោយផ្ទះ ត្រចៀកប្រុងស្តាប់ក្រែងឮសូរមាត់កូនយំ ។ ស្រីអុជចន្លុះដើរឆ្លលក្រោមគុម្ពផ្កា តាមគៀនរបង តាមរូងរន្ធផ្សេងៗ ក្រែងអ្នកណាយកកូននាងទៅលាក់នៅទីនោះ។ ធីតាយកឈើមួយកំណាត់ដើរវែកព្រៃល្បោះទាំងពួង ដើម្បីឲ្យកូននាងភ្ញាក់ឡើង យំឡើង ឲ្យនាងឮសូរសម្លេង នឹងអាលនាងបានរត់ទៅលើកឱបកូននោះមកវិញ។ កល្យាណបានយកចែវច្រវាទៅកូរក្នុងជងស្ទឹងក្រែងអ្នកណា យកកូននាងទៅចោលក្នុងទឹក។ នាងលួចសំលឹងដីណាថ្មីៗ ក្រែង

អត្ថបទដោយ៖ មាស សុភាព

គេកប់កូននាង។ លុះដល់កូនដំបូកណាមួយ ធីតាឡើងលើដំបូកនោះក្រែងបានឮសូរ រឺ បាន ឃើញកូននាង។ កន្លែងត្រង់ណាខ្មៅស្រទំគួរសង្ស័យ នាងរុកចូលទៅខំកកាយ ញែកវែករក បទុមកូនសម្លាញ់។

(សូមរង់ចាំតាមដានភាគទី១៧ នៅសប្ដាហ៍ក្រោយ)

អត្ថបទដោយៈ មាស សុភាព